**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**


**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គនាយកដ្ឋានកៅស៊ូ**


លេខ: ២៤៩ អក.សរ

ថ្ងៃ..........ខែ..........ឆ្នាំ..........ស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០២០

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ** ៖ របាយការណ៍ស្តីពីស្ថានភាពការងារអគ្គនាយកដ្ឋានកៅស៊ូប្រចាំខែសីហា ឆ្នាំ២០២០ និងទិសដៅអនុវត្តបន្ត។
**ជូនភ្ជាប់** ៖ -របាយការណ៍ស្ថានភាពការងារអគ្គនាយកដ្ឋានកៅស៊ូប្រចាំខែសីហា ឆ្នាំ២០២០...........ចំនួន០១ច្បាប់
-តារាងស្ថានភាពផលិតកម្មកៅស៊ូ និងតារាងស្ថានភាពធុរកិច្ចផលិតផលកៅស៊ូ ប្រចាំខែសីហាឆ្នាំ២០២០ ........................................................................ចំនួន០២ច្បាប់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលជ្រាបអំពីលទ្ធផលការងារសម្រេចបានរបស់អគ្គនាយកដ្ឋានកៅស៊ូប្រចាំខែសីហា ឆ្នាំ២០២០ និងទិសដៅអនុវត្តបន្តសម្រាប់ចុះក្នុងរបាយការណ៍របស់ក្រសួងក្នុងខែកញ្ញាដោយសង្ខេបដូចខាងក្រោម៖

១-ផ្ទៃដីកៅស៊ូសរុបមានចំនួន៤០៣ ១៩៥ហិកតា ក្នុងនោះ៖ ផ្ទៃដីចៀរជ័រមានចំនួន២៩០ ៦០៩ហិកតា ស្មើនឹង៧២% និងផ្ទៃដីថែទាំមានចំនួន១១២ ៥៨៦ហិកតា ស្មើនឹង៣៨%។

២-ផលិតផលជ័រកៅស៊ូក្នុងខែមានចំនួន២៩ ២៨៣តោន កើនឡើងចំនួន២ ១៦៩តោន ស្មើនឹង៨% ធៀបនឹងខែមុននិងបានកើនឡើងចំនួន៥ ៣២៣ ស្មើនឹង២២%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។ ផលិតផលជ័រកៅស៊ូមកដល់ខែនេះ មានចំនួន១៨២ ៤៩៧តោន បានកើនឡើងចំនួន៣១ ០៤៥តោន ស្មើនឹង២០%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៣-បរិមាណបញ្ញូលក់ក្នុងខែមានចំនួន២៨ ១៥៧តោន ថយចុះចំនួន១២១តោន ស្មើនឹង០.៤៣%ធៀបនឹងខែមុននឹងបានកើនឡើងចំនួន៤ ៨២០តោនស្មើនឹង២១%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។ បរិមាណបញ្ញូលក់មកដល់ខែនេះមានចំនួន១៧៩ ៦២១តោន បានកើនឡើងចំនួន៣០ ២៦៧តោន ស្មើនឹង២០%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៤-តម្លៃលក់ជ័រកៅស៊ូមធ្យមក្នុងខែថ្លៃ១ ២៦៦ដុល្លារ/តោន បានកើនឡើងចំនួន២៦ដុល្លារ/តោនស្មើនឹង២,០៩%ធៀបនឹងខែមុន និងបានថយចុះ៦៤ដុល្លារ/តោនស្មើនឹង៥%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។តម្លៃលក់កៅស៊ូមធ្យមគិតដល់ខែនេះថ្លៃ១ ២៨៨ដុល្លារ/តោន បានថយចុះចំនួន៥១ដុល្លារ/តោនស្មើនឹង៤%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៥-តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅចម្ការ គឺទឹកជ័រ (DRC 100%) ថ្លៃ៤ ១០០-៤ ៣៧៥រ/គ.ក្រ(បានធ្លាក់ថ្លៃចុះចំនួន៦រ/គ.ក្រ ធៀបនឹងខែមុន) នឹងជ័រកកថ្លៃ (DRC 50%) ថ្លៃ១ ៩០០-២ ៣៥០រ/គ.ក្រ បានកើនឡើងចំនួន៥៦រ/គ.ក្រ ធៀបនឹងខែមុន) អាស្រ័យតាមតំបន់។

៦-ទិសដៅបន្ត៖ ខិតខំអនុវត្តទិសដៅការងារដែលបានគ្រោងទុកឲ្យបានសម្រេចលទ្ធផលល្អ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ខ្ញុំបាទសូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលជ្រាបជារបាយការណ៍ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**

**ប៉ុល សុផា**

**ចម្លងជូន៖**
- ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុក
- ឯកឧត្តមអនុរដ្ឋលេខាធិការទទួលបន្ទុក
  "ដើម្បីជូនជ្រាប"
- នាយកដ្ឋានកិច្ចការរដ្ឋបាល កសក.
- នាយកដ្ឋានផែនការ និងស្ថិតិ កសក.
- នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- គ្រប់ចម្ការកៅស៊ូកសិឧស្សាហកម្ម
  "ដើម្បីជ្រាប"
- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកៅស៊ូ

# របាយការណ៍សរុប
# ស្តីពី
# ស្ថានភាពការងាររបស់អគ្គនាយកដ្ឋានកៅស៊ូ ប្រចាំខែសីហា ឆ្នាំ២០២០
# និងទិសដៅអនុវត្តបន្ត

## ១.សេចក្តីផ្តើម

ក្នុងឆ្នាំ២០២០ នេះអគ្គនាយកដ្ឋានកៅស៊ូបានអនុវត្តការងារចម្បងៗ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ទាំងការងារចរន្ត ការងារអនុវត្តគម្រោងថវិកាតាមកម្មវិធី ការងារដាំដុះ ថែទាំកូនកៅស៊ូថ្មី ការងារអាជីវកម្ម ផលិតកម្ម និងធុរកិច្ច ទាំងកៅស៊ូគ្រួសារនិងកៅស៊ូកសិឧស្សាហកម្ម និងការងារផ្សេងៗទៀតបានដំណើរការជាធម្មតា។ ជាលទ្ធផលការងារសំខាន់ៗដែលអគ្គនាយកដ្ឋានកៅស៊ូសម្រេចបានក្នុងខែសីហា ឆ្នាំ២០២០ មានខ្លឹមសារលម្អិតជូនដូចខាងក្រោម៖

## ២.លទ្ធផលការងារសម្រេចបាន

### ២.១ ការងារអាជីវកម្ម ផលិតកម្ម និងធុរកិច្ចកៅស៊ូ

#### ២.១.១ ផ្ទៃដីកៅស៊ូ

ផ្ទៃដីកៅស៊ូសរុបមានចំនួន៤០៣ ១៩៥ ហិកតា ដែលក្នុងនោះ៖ ផ្ទៃដីចៀរជ័រមានចំនួន២៩០ ៦០៩ហិកតា ស្មើនឹង៧២% និងផ្ទៃដីថែទាំមានចំនួន១១២ ៥៨៦ហិកតា ស្មើនឹង២៨%។

#### ២.១.២ ផលិតកម្ម

- ផលិតផលជ័រកៅស៊ូសម្រេចបានប្រចាំខែសីហា ឆ្នាំ២០២០ មានចំនួន២៩ ២៨៣តោន បានកើនឡើងចំនួន២ ១៦៩តោនស្មើនឹង៨%ធៀបនឹងខែមុននិងបានកើនឡើងចំនួន៥ ៣២៣តោនស្មើនឹង២២%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។

- ផលិតផលជ័រកៅស៊ូសរុបគិតមកដល់ខែសីហា ឆ្នាំ២០២០ សម្រេចបានចំនួន១៨២ ៩៩៧បានកើនឡើងចំនួន៣១ ០៤៥តោន ស្មើនឹង២០% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

#### ២.១.៣ ធុរកិច្ចកៅស៊ូ

- បរិមាណបញ្ចេញលក់ជ័រកៅស៊ូសម្រេចបានក្នុងខែសីហា ឆ្នាំ២០២០ មានចំនួន២៨ ១៥៧តោន បានថយចុះចំនួន១២១តោន ស្មើនឹង០.៤៣%ធៀបនឹងខែមុននិងបានកើនឡើងចំនួន៤ ៨២០តោនស្មើនឹង២១%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។

- បរិមាណបញ្ចេញលក់សរុបគិតមកដល់ខែសីហា ឆ្នាំ២០២០ សម្រេចបានចំនួន១៧៩ ៦២១តោន កើនឡើងចំនួន៣០ ២៦៧តោន ស្មើនឹង២០%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

ផ្លូវជាតិលេខ៦អា ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កម្ពុជា
National Road No.6A, Phum Bakkheng, Sangkat Prek Leap, Khan Chroy Changva, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៦៧២២ ៥៩០
Phone: (855) 23 6722 590, Email: gdr.maff@gmail.com

- តម្លៃលក់មធ្យមជ័រកៅស៊ូក្នុងខែសីហា ឆ្នាំ២០២០ មានចំនួន ១ ២៦៦ដុល្លារ/តោន បានកើនឡើងចំនួន២៦ដុល្លារ/តោន ស្មើនឹង២,០៩%ធៀបនឹងខែមុន និងបានថយចុះចំនួន៦៤ដុល្លារ/តោនស្មើនឹង៥%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។

- តម្លៃលក់កៅស៊ូជាមធ្យមគិតមកដល់ខែសីហា ឆ្នាំ២០២០ គឺ១ ២៨៨ ដុល្លារ/តោន បានថយចុះចំនួន៥១ដុល្លារ/តោន ស្មើនឹង៤% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅចម្ការ គឺទឹកជ័រ (DRC 100%) ថ្លៃ៤ ១០០-៤ ៣៧៥៛/គ.ក្រ(បានធ្លាក់ថ្លៃចំនួន៦៛/គ.ក្រ ធៀបនឹងខែមុន) និងជ័រកក (DRC 50%) ថ្លៃ១ ៩០០-២ ៣៥០៛/គ.ក្រ បានកើនឡើងចំនួន៥៦៛/គ.ក្រ ធៀបនឹងខែមុន) អាស្រ័យតាមតំបន់។

## ២.២. ការងារចរន្តនិងការអនុវត្តគម្រោងសកម្មភាពថវិកាតាមកម្មវិធី

### ២.២.១. ការងារចរន្ត

- ប្រជុំប្រកាស ស្ដីពីនិតិវិធីនៃការផ្តល់លិខិតអនុញ្ញាតបង្កើតរោងចក្រសិប្បកម្មកែច្នៃកៅស៊ូ និងឈើកៅស៊ូ
- ចុះបើកវគ្គចងក្រងសហគមន៍កសិកម្មកៅស៊ូគ្រួសារ នៅស្រុកអូរយ៉ាដាវ ខេត្តរតនគីរីមានពីរជំហ៊ាន (១)នៅថ្ងៃទី០៩-១២ ខែសីហា ឆ្នាំ២០២០ (២) នៅថ្ងៃទី២៥-២៨ ខែសីហា ឆ្នាំ២០២០
- ចូលរួមពិនិត្យ និងកែសម្រួលលើការបំពេញទំរង់បែបបទនៃការដាក់ពាក្យសុំកិច្ចសហប្រតិបត្តិកាជាមួយប្រទេសជប៉ុនលើអនុវិស័យកៅស៊ូ
- ពិនិត្យ និងរៀបចំលទ្ធផលដែលសម្រេចបានរបស់សកម្មភាពនីមួយៗនៃយុទ្ធសាស្រ្តសម្រាប់ការអភិវឌ្ឍន៍កៅស៊ូធម្មជាតិនៅកម្ពុជា(២០១១-២០២០)របស់នាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ
- បញ្ចូលទិន្នន័យការចំណាយសរុបទៅតាមសកម្មភាពនីមួយៗ របស់អគ្គនាយកដ្ឋានកៅស៊ូសម្រាប់ឆ្នាំ២០២០ ក្នុងនោះរួមមាន(១)បណ្តុះបណ្តាលបច្ចេកទេសកៅស៊ូដល់កសិករកៅស៊ូគ្រួសារ(២) ពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារ និង(៣) ចងក្រងសហគមន៍កសិកម្មកៅស៊ូគ្រួសារ
- រៀបចំបទបង្ហាញស្តីអំពីការប្រើប្រាស់ជីគីមីលើដំណាំកៅស៊ូ ដើម្បីចូលរួមសិក្ខាសាលាផ្ទេរបច្ចេកវិទ្យាដំណាំកៅស៊ូដល់មន្ត្រីបង្គោលនៅតាមបណ្តាខេត្តដែលមានដាំកៅស៊ូ
- បានចុះពិនិត្យករណីប្រជាពលរដ្ឋ២១គ្រួសារស្នើសុំកិច្ចអន្តរាគមន៍ ចំពោះក្រុមហ៊ុនអានម៉ាឌីគ្រុបពាក់ព័ន្ធនឹងការសាងសង់របងលួសបន្លាហ៊ុមព័ទ្ធចម្ការកៅស៊ូ
- រៀបចំសិក្ខាសាលាស្តីពីស្ថានភាពកៅស៊ូធម្មជាតិ នៅសណ្ឋាគារភ្នំប្រុស ខេត្តកំពង់ចាម
- រៀបចំពិនិត្យ និងបូកសរុបគម្រោងសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២១
- តាមដានត្រួតពិនិត្យ ស្រាវជ្រាវអំពីថ្លៃកៅស៊ូនៅទីផ្សារក្នុងនិងក្រៅស្រុកប្រមូល និងចងក្រងទិន្នន័យតម្លៃទិញ-លក់កៅស៊ូធម្មជាតិប្រចាំថ្ងៃ
- បានពិនិត្យ ពិភាក្សាកែសម្រួលខ្លឹមសារនិងតួលេខ លើរបាយការណ៍ផែនការអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាមដែលភាគីវៀតណាមផ្ញើមកលើកចុងក្រោយ
- ប្រជុំពិនិត្យនិសម្រេចព្រឹត្តបត្រកៅស៊ូធម្មជាតិប្រចាំខែកក្កដា វឌ្ឍនភាពខែសីហា និងលើកទិសដៅខែកញ្ញា ឆ្នាំ២០២០ និងបោះពុម្ពព្រឹត្តបត្រកៅស៊ូប្រចាំខែមិថុនា ចំនួន១៨០ច្បាប់។
- បានប្រជុំនិងប្រមូលធាតុចូលសំខាន់ផ្សេងៗពីនាយកដ្ឋានពាក់ព័ន្ធសម្រាប់ដាក់បញ្ចូលទៅក្នុង GDR Website Guideline ដោយពិនិត្យលម្អិតលើ Menu គេហទំព័រនិងការបង្កើត App របស់GDR នៅពេលអនាគត និងបច្ចុប្បន្នកំពុងស្នើសុំឈ្មោះSub-Domain ថ្មីពីក្រសួងកសិកម្មនិងគ្រោងរៀបចំធ្វើបច្ចុប្បន្នភាពមុខងារគេហទំព័រ GDR ជាមួយនឹង Web Developer។

### ២.២.២. ការចំណាយថវិកាតាមគម្រោងកម្មវិធី

ការចំណាយថវិការហូតដល់ខែសីហា ឆ្នាំ២០២០ មានចំនួន៨៣៥ ៣០០ ៤១៨រៀលស្មើនឹង៦៣,៨៧ភាគរយ នៃផែនការធ្វើវិចារណកម្មការចំណាយថវិកាទាំងពីរលើកមានចំនួន១ ៣០៧ ៩០០ ០០០រៀល។ (សម្រាប់ក្នុងខែសីហាមានចំនួន១៣៥ ៧៧៤ ៤០០រៀល)

### ២.២.៣. ការប្រមូលចំណូលថវិកា

ការប្រមូលចំណូលរហូតដល់ខែសីហានេះ អនុវត្តបានចំនួន៦០៨ ៥៦៤ ៥៥៣រៀល ស្មើនឹង៣៨,៨៦ ភាគរយ នៃផែនការ(សម្រាប់ក្នុងខែសីហាពុំទាន់ដល់ការបរិច្ឆេទត្រូវបង់ថ្លៃឈ្នួល)។

## ៣. ទិសដៅបន្ត

- បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យកៅស៊ូ
- បន្តចុះផ្សព្វផ្សាយនិងចងក្រងបង្កើតសហគមន៍កសិករកៅស៊ូគ្រួសារ
- រៀបចំឯកសារមេរៀនសម្រាប់ចុះបើកវគ្គសិក្ខាសាលាផ្ទេរបច្ចេកវិទ្យាដំណាំកៅស៊ូដល់មន្ត្រីបង្គោល
- បន្តចុះពិនិត្យ និងវាយតម្លៃបច្ចេកទេសដំណាំកៅស៊ូរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច
- បន្តអនុវត្តគម្រោងផែនការសកម្មភាពថវិកាកម្មវិធីសម្រាប់ឆ្នាំ២០២០
- បន្តរៀបចំគម្រោងផែនការសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២១
- រៀបចំបញ្ជូនសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០ ទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បន្តខិតខំផ្សព្វផ្សាយតម្លៃជ័រកៅស៊ូធម្មជាតិ នៅលើទីផ្សារក្នុងស្រុកនិងអន្តរជាតិតាមបណ្តាញសង្គម (ហ្វេសប៊ុក)ឲ្យបានដល់កសិករកៅស៊ូគ្រួសារ និងប្រតិបត្តិករកៅស៊ូ
- បន្តសិក្សាស្រាវជ្រាវផ្សព្វផ្សាយពត៌មានអំពីការផ្គត់ផ្គង់ តម្រូវការ ការប្រើប្រាស់កៅស៊ូធម្មជាតិនិងនិន្នាការតម្លៃកៅស៊ូលើទីផ្សារក្នុងនិងក្រៅប្រទេស
- បន្តខិតខំធ្វើទំនាក់ទំនងកិច្ចសហប្រត្តិបត្តិការជាមួយដៃគូរអភិវឌ្ឍ ទីភ្នាក់ងារកៅស៊ូ និងអង្គការកៅស៊ូអន្តរជាតិនានាក្នុងក្របខណ្ឌការងារស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យា វិទ្យាសាស្ត្រ
- បន្តរៀបចំផែនការសកម្មភាពការងារសំណើគម្រោង និងទស្សនាទាននៃគម្រោងពាក់ព័ន្ធនឹងវិស័យឧស្សាហកម្មកៅស៊ូធម្មជាតិ
- បន្តតាមដានលើវឌ្ឍនភាព នៃកិច្ចសហប្រត្តិបត្តិការជាមួយបណ្តាប្រទេសជាដៃគូរ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូបានប្រគល់អោយ។

ថ្ងៃ សុក្រ ៩ កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០២០
**ប្រធាននាយកដ្ឋានរដ្ឋបាល និងនីតិកម្ម**

យួន_ផល្លា

**បានឃើញនិងឯកភាព**
**ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**
**អគ្គនាយករង**

ចាន់_វឌ្ឍនា

# អគ្គនាយកដ្ឋានកៅស៊ូ
## នាយកដ្ឋានរដ្ឋបាល និងនីតិកម្ម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ស្ថានភាពផលិតកម្មកៅស៊ូប្រចាំខែសីហា ឆ្នាំ២០២០

តារាងទី១

| ល.រ | ចម្ការកៅស៊ូ | ផ្ទៃដី(ហិកតា) | | | ឆ្នាំ២០១៩ | | | | សន្និធិដើមឆ្នាំ | ឆ្នាំ២០២០ | | | | ប្រៀបធៀប | | | | | | | | | | | | | | សន្និធិ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ផលិតផល(តោន) | | បញ្ញលក់(តោន) | | | ផលិតផល(តោន) | | បញ្ញលក់(តោន) | | ខែមុន | | | | | | រយៈពេលដូចគ្នាឆ្នាំមុន | | | | | | | | |
| | | | | | | | | | | | | | | ផ្ទៃដីសរុប | | ផលិតផល | | បញ្ញលក់ | | ផលិតផល | | | | បញ្ញលក់ | | | | |
| | | ចៀរជ័រ | ថែទាំ | សរុប | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | | | | | | | ខែនេះ | | ដល់ខែនេះ | | ខែនេះ | | ដល់ខែនេះ | | |
| | | | | | | | | | | | | | | ហិកតា | % | តោន | % | តោន | % | តោន | % | តោន | % | តោន | % | តោន | % | |
| | I. កៅស៊ូកសិឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | |
| ក | ចម្ការកៅស៊ូកសិឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | |
| 1 | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | 670 | 132 | 801 | 35 | 282 | | 200 | 158 | 44 | 242 | - | 15 | 0 | 0 | -1 | -3 | 0 | 0 | 9 | 25 | -40 | -14 | 0 | 0 | -185 | -93 | 385 |
| 2 | ក្រុមហ៊ុនសុភក្តិនីកា អ៊ីនវេសមេន គ្រុប | 11.287 | 3.262 | 14.549 | 1.522 | 9.477 | 1.459 | 9.505 | 1.093 | 1.470 | 10.326 | 1.510 | 10.595 | 0 | 0 | -224 | -13 | -807 | -35 | -52 | -3 | 849 | 9 | 51 | 3 | 1.090 | 11 | 823 |
| 3 | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | 1.259 | 1.106 | 2.365 | 160 | 951 | 231 | 903 | 21 | 171 | 783 | 189 | 798 | 0 | 0 | 25 | 17 | 63 | 50 | 11 | 7 | -169 | -18 | -42 | -18 | -105 | -12 | 6 |
| 4 | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខូអិលធីឌី | 6.092 | 1.964 | 8.057 | 454 | 2.559 | 386 | 2.702 | 618 | 552 | 2.931 | 266 | 2.858 | 0 | 0 | 1 | 0 | -503 | -65 | 98 | 22 | 371 | 15 | -120 | -31 | 155 | 6 | 691 |
| 5 | ក្រុមហ៊ុនស៊ីហ្វ វ៉ាប់ប៊ើ លីមីតធីត(រតនគិរី) | 306 | 2.418 | 2.724 | 18 | 151 | 29 | 141 | 47 | 39 | 244 | - | 169 | 0 | 0 | -17 | -30 | 0 | 0 | 21 | 116 | 93 | 61 | -29 | 0 | 28 | 20 | 121 |
| 6 | ក្រុមហ៊ុនស៊ីហ្វ រីសសស៍ លីមីធីត(ស្នួល) | 4.174 | 76 | 4.250 | 495 | 2.304 | 600 | 2.861 | 1.911 | 589 | 2.492 | 252 | 2.595 | 0 | 0 | 80 | 16 | -131 | -34 | 94 | 19 | 188 | 8 | -348 | -58 | -266 | -9 | 1.808 |
| 7 | ក្រុមហ៊ុនឡុងស្រេងអ៊ីនធើណេស៊ិនណល | 3.908 | 278 | 4.186 | 495 | 1.706 | 600 | 2.322 | 706 | 401 | 1.777 | 310 | 2.246 | 0 | 0 | 48 | 14 | -110 | -26 | -95 | -19 | 71 | 4 | -290 | -48 | -76 | -3 | 237 |
| 8 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ចម្ការអណ្តូង) | 3.312 | 1.570 | 4.882 | 192 | 1.119 | | 1.107 | 613 | 198 | 1.049 | 250 | 1.088 | 0 | 0 | -1 | -1 | 115 | 85 | 7 | 3 | -70 | -6 | 250 | 100 | -18 | -2 | 574 |
| 9 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ពាមជាំង+រមាសហែក) | 1.918 | 1.119 | 3.037 | 158 | 744 | | 734 | 380 | 134 | 571 | 160 | 619 | 0 | 0 | 41 | 45 | 110 | 220 | -24 | -15 | -173 | -23 | 160 | 100 | -115 | -16 | 332 |
| 10 | ក្រុមហ៊ុនក្រែក(ខេមបូឌា) ខូអិលធីឌី | 4.639 | 159 | 4.798 | 630 | 3.758 | 831 | 4.107 | 550 | 485 | 3.283 | 420 | 3.137 | 0 | 0 | -84 | -15 | -357 | -46 | -145 | -23 | -475 | -13 | -411 | -49 | -970 | -24 | 697 |
| | សរុប ក | 37.566 | 12.085 | 49.651 | 4.160 | 23.052 | 4.137 | 24.583 | 6.097 | 4.083 | 23.697 | 3.357 | 24.121 | 0 | 0 | -131 | -3 | -1.621 | -33 | -77 | -2 | 645 | 3 | -780 | -19 | -462 | -2 | 5.673 |
| ខ | ចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច | 104.999 | 87.443 | 192.442 | 8.000 | 52.100 | 7.600 | 49.900 | 3.653 | 10.600 | 66.400 | 10.500 | 65.400 | 0 | 0 | 1.300 | 14 | 500 | 5 | 2600 | 33 | 14.300 | 27 | 2.900 | 38 | 15.500 | 31 | 4.653 |
| | សរុបI=ក+ខ | 142.565 | 99.528 | 242.093 | 12.160 | 75.152 | 11.737 | 74.483 | 9.750 | 14.683 | 90.097 | 13.857 | 89.521 | 0 | 0 | 1.169 | 9 | -1.121 | -7 | 2523 | 21 | 14.945 | 20 | 2.120 | 18 | 15.038 | 20 | 10.326 |
| | II. កៅស៊ូគ្រួសារ | 148.044 | 13.058 | 161.103 | 11.800 | 76.300 | 11.600 | 74.900 | 7.076 | 14.600 | 92.400 | 14.300 | 90.100 | 0 | 0 | 1.000 | 7 | 1.000 | 8 | 2800 | 24 | 16.100 | 21 | 2.700 | 23 | 15.200 | 20 | 9.376 |
| | សរុបរួមI+II | 290.609 | 112.586 | 403.195 | 23.960 | 151.452 | 23.337 | 149.383 | 16.826 | 29.283 | 182.497 | 28.157 | 179.621 | 0 | 0 | 2.169 | 8 | -121 | -0,43 | 5323 | 22 | 31.045 | 20 | 4.820 | 21 | 30.238 | 20 | 19.702 |

**បញ្ជាក់៖**

(១) ផ្ទៃដីសរុបមានចំនួន៤០៣ ១៩៥ហត ( ផ្ទៃដីចៀរជ័រ២៩០ ៦០៩ ហត ថែទាំ ១១២ ៥៨៦ហត) ។

(២) ផលិតផលក្នុងខែសីហាមានចំនួន២៩ ២៨៣តោន បានកើនឡើងចំនួន២ ១៦៩តោន ( ៨%) ធៀបនិងខែមុននឹងបានកើនឡើងចំនួន៥ ៣២៣ (២២%)រយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

(៣) រហូតមកដល់ខែសីហា ឆ្នាំ២០២០ ផលិតផលសរុប១៨២ ៤៩៧តោន បានកើនឡើងចំនួន៣១ ០៤៥តោន (២០%)ធៀបនិងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

(៤) ការបញ្ញលក់ក្នុងខែសីហាមានចំនួន២៨ ១៥៧តោន បានថយចុះចំនួន ១២១តោន (០.៤៣%)ធៀបនិងខែមុននឹងបានកើនឡើងចំនួន៤ ៨២០(២១%)រយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

(៥) រហូតមកដល់ខែសីហា ឆ្នាំ២០១៩ ការបញ្ញលក់សរុបចំនួន១៧៩ ៦២១តោន បានកើនឡើងចំនួន៣០ ២៦៧តោន (២០%) ធៀបនិងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

(៦)សន្និធិចុងគ្រាមានចំនួន១៩ ៧០២តោន

**បានឃើញ និងឯកភាព**
**ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**
**អគ្គនាយករង**

**ចាន់_វឌ្ឍនា**

**បានពិនិត្យត្រឹមត្រូវ**
**ប្រធាននាយកដ្ឋានរដ្ឋបាល និងនីតិកម្ម**

**យួន_ផល្លា**

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២០
អ្នកធ្វើតារាង

អគ្គនាយកដ្ឋានកៅស៊ូ

នាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## តារាងស្ថានភាពធុរកិច្ចផលិតផលជ័រកៅស៊ូស្ងួតប្រចាំខែសីហា ឆ្នាំ២០២០

តារាងទី២

| ល.រ | ចម្ការកៅស៊ូ | សីហា ២០១៩ | | | | | | សីហា ២០២០ | | | | | | ធៀបខែមុន | | | | ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំមុន | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | បរិមាណ | | តម្លៃមធ្យម | | បរិមាណ | | | | តម្លៃមធ្យម | | | |
| | | បរិមាណ(តោន) | | ទឹកប្រាក់($) | | តម្លៃមធ្យម($/តោន) | | បរិមាណ(តោន) | | ទឹកប្រាក់($) | | តម្លៃមធ្យម($/តោន) | | ខែនេះ | | ខែនេះ | | ខែនេះ | | ដល់ខែនេះ | | ខែនេះ | | ដល់ខែនេះ | |
| | | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | តោន | % | $/តោន | % | តោន | % | តោន | % | $/តោន | % | $/តោន | % |
| | I. ចម្ការកៅស៊ូកសិ-ឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | |
| ក | កៅស៊ូកសិ-ឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | |
| 1 | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | | 200 | | 251.500 | 0 | 1.258 | | 15 | | 14.500 | 0 | 967 | 0 | 0,00 | 0 | 0,00 | 0 | 0 | -185 | -93 | 0 | 0 | -291 | -23 |
| 2 | ក្រុមហ៊ុនសុភក្តិនីកា អ៊ីនវេសមេន គ្រុប | 1.459 | 9.505 | 2.015.321 | 12.902.038 | 1.381 | 1.357 | 1.510 | 10.595 | 1.950.318 | 13.476.805 | 1.292 | 1.272 | -807 | -34,83 | 47 | 3,75 | 51 | 3 | 1.090 | 11 | -89 | -6 | -85 | -6 |
| 3 | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | 231 | 903 | 284.130 | 1.176.840 | 1.230 | 1.303 | 189 | 798 | 232.260 | 983.589 | 1.229 | 1.233 | 63 | 50,00 | 31 | 2,62 | -42 | -18 | -105 | -12 | -1 | 0 | -71 | -5 |
| 4 | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខូអិលធីឌី | 386 | 2.702 | 539.376 | 3.756.064 | 1.396 | 1.390 | 266 | 2.858 | 340.591 | 3.915.996 | 1.279 | 1.370 | -503 | -65,39 | 21 | 1,70 | -120 | -31 | 155 | 6 | -117 | -8 | -20 | -1 |
| 5 | ក្រុមហ៊ុនស៊ីហ្វ រ៉ាប់ប៊ើ លីមីតធីត(រតនគិរី) | 29 | 142 | 27.928 | 156.194 | 950 | 1.102 | | 169 | | 173.004 | 0 | 1.022 | 0 | 0,00 | 0 | 0,00 | -29 | 0 | 28 | 19 | -950 | 0 | -80 | -7 |
| 6 | ក្រុមហ៊ុនស៊ីហ្វ រីសសស៍ លីមីធីត(ស្នួល) | 600 | 2.861 | 805.900 | 3.725.010 | 1.343 | 1.302 | 252 | 2.595 | 326.340 | 3.301.206 | 1.295 | 1.272 | -131 | -34,17 | 104 | 8,70 | -348 | -58 | -266 | -9 | -48 | -4 | -30 | -2 |
| 7 | ក្រុមហ៊ុនឡុងស្រេងអ៊ីនធើណេស៊ិនណល | 600 | 2.322 | 760.000 | 3.113.365 | 1.267 | 1.341 | 310 | 2.246 | 392.250 | 3.053.104 | 1.265 | 1.359 | -110 | -26,19 | -2 | -0,17 | -290 | -48 | -76 | -3 | -1 | 0 | 19 | 1 |
| 8 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ចម្ការអណ្តូង) | | 1.107 | | 1.372.754 | 0 | 1.240 | 250 | 1.088 | 293.250 | 1.292.425 | 1.173 | 1.187 | 115 | 84,64 | -38 | -3,17 | 250 | 100 | -18 | -2 | 1.173 | 100 | -53 | -4 |
| 9 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ពាមជាំង) | | 734 | | 920.116 | 0 | 1.253 | 160 | 619 | 190.200 | 728.074 | 1.189 | 1.177 | 110 | 220,00 | -26 | -2,16 | 160 | 100 | -115 | -16 | 1.189 | 100 | -77 | -6 |
| 10 | ក្រុមហ៊ុនក្រែក(ខេមបូឌា) ខូអិលធីឌី | 831 | 4.107 | 1.071.120 | 5.436.810 | 1.289 | 1.324 | 420 | 3.137 | 525.000 | 3.983.610 | 1.250 | 1.270 | -357 | -45,95 | 19 | 1,54 | -411 | -49 | -970 | -24 | -39 | -3 | -54 | -4 |
| | **សរុប ក** | **4.137** | **24.583** | **5.503.774** | **32.810.691** | **1.330** | **1.335** | **3.357** | **24.121** | **4.250.209** | **30.922.313** | **1.266** | **1.282** | **-1.621** | **-32,55** | **26** | **2,09** | **-780** | **-19** | **-463** | **-2** | -64 | **-5** | -53 | **-4** |
| ខ | កៅស៊ូសម្បទានដីសេដ្ឋកិច្ច | 7.600 | 49.900 | 10.110.192 | 66.866.909 | 1.330 | 1.340 | 10.500 | 65.400 | 13.292.346 | 84.295.459 | 1.266 | 1.289 | 500 | 5,00 | 26 | 2,09 | 2.900 | 38 | 15.500 | 31 | -64 | -5 | -51 | -4 |
| | សរុបI=ក+ខ | 11.737 | 74.483 | 15.613.966 | 99.677.600 | 1.330 | 1.338 | 13.857 | 89.521 | 17.542.555 | 115.217.772 | 1.266 | 1.287 | -1.121 | -7,48 | 26 | 2,09 | 2.120 | 18 | 15.037 | 20 | -64 | -5 | -51 | -4 |
| | II.ចម្ការកៅស៊ូគ្រួសារ | 11.600 | 74.900 | 15.431.346 | 100.341.252 | 1.330 | 1.340 | 14.300 | 90.100 | 18.102.909 | 116.181.825 | 1.266 | 1.289 | 1.000 | 7,52 | 26 | 2,09 | 2.700 | 23 | 15.200 | 20 | -64 | -5 | -50 | -4 |
| | **សរុបI+II** | **23.337** | **149.383** | **31.045.312** | **200.018.852** | **1.330** | **1.339** | **28.157** | **179.621** | **35.645.464** | **231.399.597** | **1.266** | **1.288** | **-121** | **-0,43** | **26** | **2,09** | **4.820** | **21** | **30.237** | **20** | -64 | **-5** | -51 | **-4** |

**បញ្ជាក់៖**

១. ក្នុងខែសីហា ឆ្នាំ២០២០ បរិមាណបញ្ចេញលក់សរុបមានចំនួន២៨ ១៥៧តោន បានថយចុះចំនួន១២១តោន (=-0,៤៣%) ធៀបនឹងខែមុន ប៉ុន្តែបានកើនឡើងចំនួន៤ ៨២០តោន (=+២១%) ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

២. ក្នុងខែសីហា ឆ្នាំ២០២០ តម្លៃលក់មធ្យមគឺ១ ២៦៦US$/តោន បានកើនឡើងចំនួន២៦US$/តោន (=+២,០៩%) ធៀបនឹងខែមុន ប៉ុន្តែបានថយចុះចំនួន៦៤US$/តោន (=-៥%) ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

៣. រហូតដល់ខែសីហា ឆ្នាំ២០២០ (រយៈពេល ៨ខែ) បរិមាណបញ្ចេញលក់សរុបមានចំនួន១៧៩ ៦២១តោន បានកើនឡើង៣០ ២៣៧តោន (=+២០%) ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៩។

៤. រហូតដល់ខែសីហា ឆ្នាំ២០២០ (រយៈពេល ៨ខែ) តម្លៃលក់មធ្យមគឺ១ ២៨៨US$/តោន បានថយចុះ៥១US$/តោន (=-៤%) ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៩។

បានឃើញ និងឯកភាព

ឧ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ

អគ្គនាយករង

យុន កក្កដា

បានពិនិត្យត្រឹមត្រូវ

ប្រធាននាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ

ថ្ងៃ ... ខែ ... ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ ... ឆ្នាំ២០២០

អ្នកធ្វើតារាង

អគ្គនាយកដ្ឋានកៅស៊ូ
នាយកដ្ឋានទីផ្សារ និងសហប្រតិបត្តិការអន្តរជាតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ថ្លៃប្រមូលទិញជ័រកៅស៊ូពីកសិករកៅស៊ូគ្រួសារ

*ខែសីហា ឆ្នាំ២០២០*

| ល.រ | ខេត្ត | សប្តាហ៍ទី ១ | | | | | | សប្តាហ៍ទី ២ | | | | | | សប្តាហ៍ទី ៣ | | | | | | សប្តាហ៍ទី ៤ | | | | | | តម្លៃមធ្យមខែ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | ជ័រកក |
| | | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (រ/គ.ក្រ) | រ/គ.ក្រ | រ/គ.ក្រ |
| ១ | កំពង់ចាម | 4.400 | 1,07 | ↓ 200 | 2.200 | 0,54 | ↓ 100 | 4.400 | 1,07 | → 0 | 2.200 | 0,54 | → 0 | 4.400 | 1,07 | → 0 | 2.200 | 0,54 | → 0 | 4.300 | 1,03 | ↓ 100 | 2.100 | 0,50 | ↓ 100 | 4.375 | 2175 |
| ២ | ត្បូងឃ្មុំ | 4.200 | 1,03 | → 0 | 2.250 | 0,55 | → 0 | 4.200 | 1,03 | → 0 | 2.250 | 0,55 | → 0 | 4.200 | 1,03 | → 0 | 2.250 | 0,55 | → 0 | 4.600 | 1,10 | ↑ 400 | 2.350 | 0,56 | ↑ 100 | 4.300 | 2275 |
| ៣ | កំពង់ធំ | 4.100 | 1,00 | → 0 | 2.000 | 0,49 | → 0 | 4.100 | 1,00 | → 0 | 2.000 | 0,49 | → 0 | 4.100 | 1,00 | → 0 | 2.000 | 0,49 | → 0 | 4.100 | 0,98 | → 0 | 2.000 | 0,48 | → 0 | 4.100 | 2000 |
| ៤ | រតនគិរី | 4.200 | 1,03 | ↑ 100 | 2.200 | 0,54 | → 0 | 4.200 | 1,03 | → 0 | 2.200 | 0,54 | → 0 | 4.200 | 1,03 | → 0 | 2.200 | 0,54 | → 0 | 4.300 | 1,03 | ↑ 100 | 2.400 | 0,57 | ↑ 200 | 4.225 | 2250 |
| ៥ | ក្រចេះ | | 0,00 | → 0 | 1.900 | 0,46 | → 0 | | 0,00 | → 0 | 1.900 | 0,46 | → 0 | | 0,00 | → 0 | 1.900 | 0,46 | → 0 | | 0,00 | → 0 | 1.900 | 0,45 | → 0 | | 1900 |
| ៦ | មណ្ឌលគិរី | | | | 2.350 | 0,57 | → 0 | | | | 2.350 | 0,57 | → 0 | | | | 2.350 | 0,57 | → 0 | | | | 2.350 | 0,56 | → 0 | | 2350 |
| តម្លៃមធ្យម | | 4.225 | 1,03 | ↓ 25 | 2.150 | 0,53 | ↓ 17 | 4.225 | 1,03 | → 0 | 2.150 | 0,53 | → 0 | 4.225 | 1,03 | → 0 | 2.150 | 0,53 | → 0 | 4.325 | 1,03 | ↑ 100 | 2.183 | 0,52 | ↑ 33 | 4.250 | 2.158 |
| អត្រាប្តូរប្រាក់ធនាគារជាតិនៃកម្ពុជា | | | 4.095 | | | | | | 4.095 | | | | | | 4.095 | | | | | | 4.192 | | | | | | |

ក្នុងខែសីហា ឆ្នាំ២០២០ ថ្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅមាត់ចម្ការ គឺទឹកជ័រ ថ្លៃ៤១០០-៤៣៧៥រ/គ.ក្រ (ធ្លាក់ចុះចំនួន៦រ/គ.ក្រ ធៀបខែមុន) និងជ័រកក ថ្លៃ១៩០០-២៣៥០រ/គ/ក្រ (កើនឡើងចំនួន៥៦រ/គ.ក្រ ធៀបខែមុន) អាស្រ័យតាមតំបន់។

**បញ្ជាក់៖**

*ប្រភព: ពីអ្នកប្រមូលទិញតាមតំបន់*

*ទឹកជ័រ: គិតជាស្ងួត (DRC)*

*ជ័រកក: DRC ≅ 50%*

**បានឃើញ និងឯកភាព**
**ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**
**អគ្គនាយករង**

ឃុន ភក្កដា

**បានពិនិត្យត្រឹមត្រូវ**
**ប្រធាននាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ**

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២០
**អ្នកធ្វើតារាង**